អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ភ្នំពេញ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៥

# សេចក្តីប្រកាសព័ត៌មាន
# បទចោទប្រកាន់អំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ នឹងត្រូវលើកមកសួរដេញដោលជាលើកដំបូងនៅចំពោះមុខ អ.វ.ត.ក

ចាប់ពីថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ តទៅ ហើយក៏ជាលើកទី១ដែរ ដែលអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នឹងបើកសវនាការដេញដោលលើភស្តុតាងទាក់ទងនឹងបទចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ នៅពេលដែលការជំនុំជម្រះក្តីលើសំណុំរឿង ០០២/០២ ប្រឆាំងនឹងជនជាប់ចោទ ខៀវ សំផន និង នួន ជា បានឈានដល់ការជំនុំជម្រះលើអង្គហេតុថ្មីមួយទៀតផ្តោតលើការចោទប្រកាន់ទាក់ទងនឹងការប្រព្រឹត្តទៅលើក្រុមជនជាតិចាម។ សាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៤ រូប និង អ្នកជំនាញ ១រូប នឹងត្រូវកោះហៅមកផ្តល់សក្ខីកម្មនៅអំឡុងពេលនៃការជំនុំជម្រះលើអង្គហេតុនេះ។

ជនជាតិចាមគឺជាជនជាតិភាគតិចមួយនៅក្នុងប្រទេសកម្ពុជាដែលមានភាសាដូចគ្នា វប្បធម៌ដូចគ្នា និងសាសនាដូចគ្នាគឺសាសនាឥស្លាម។ យោងតាមដីកាដំណោះស្រាយ ជនជាតិចាមត្រូវបានគេកំណត់មុខសញ្ញា និងសម្លាប់ជាលក្ខណៈប្រព័ន្ធ ហើយបក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តគោលនយោបាយបំផ្លិចបំផ្លាញទាំងស្រុង ឬ មួយផ្នែកលើក្រុមជនជាតិចាម។ ដីកាដំណោះស្រាយបានបង្ហាញថា ជនជាតិចាមត្រូវបានកំណត់គោលដៅជាលក្ខណៈប្រព័ន្ធ ហើយត្រូវបានសម្លាប់ ដោយសារតែសមាជិកភាពរបស់ពួកគេនៅក្នុងក្រុមជនជាតិចាមនេះ ហើយក៏ត្រូវបានផ្លាស់ទីលំនៅដោយបង្ខំ និង បានបញ្ចូលទៅក្នុងភូមិរបស់ប្រជាជនខ្មែរ ព្រមទាំងបានហាមឃាត់មិនឱ្យមានការគោរពប្រតិបត្តិសាសនារបស់ពួកគេផងដែរ។ តាមដីកាដំណោះស្រាយដដែល ថ្នាក់ដឹកនាំសាសនាឥស្លាម និង ប្រជាជនចាស់ទុំ និង អ្នកដែលនៅតែបន្តអនុវត្តសាសនារបស់ពួកគេនឹងត្រូវឃុំខ្លួន ហើយបន្ទាប់មកនឹងត្រូវសម្លាប់ចោល។ វប្បធម៌ និង ភាសាចាម ហើយនឹងសម្លៀកបំពាក់របស់បងប្អូនចាម ត្រូវបានហាមឃាត់។ ដីកាដំណោះស្រាយបានបង្ហាញភស្តុតាងថា ជនជាតិចាមប្រមាណ ៣៦% នៅក្នុងប្រទេសកម្ពុជាត្រូវបានសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដីកាដំណោះស្រាយ ក៏បានចោទប្រកាន់ថា នួន ជា និង ខៀវ សំផន តាមរយៈតួនាទីផ្សេងៗរបស់គាត់ក្នុងបក្សកុម្មុយនិស្តកម្ពុជា គឺជាអ្នកទទួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងប្រឆាំងនឹងក្រុមជនជាតិចាម។

សំណុំរឿង ០០២/០២ គឺជាការជំនុំជម្រះក្តីលើកទី២ ប្រឆាំងនឹង នួន ជា និង ខៀវ សំផន ដោយរាប់បញ្ចូលបទចោទប្រកាន់អំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម និង ជនជាតិវៀតណាម ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និង ការរំលោភផ្លូវភេទនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការ

បោសសម្អាតផ្ទៃក្នុង ការប្រព្រឹត្តមកលើពុទ្ធសាសនិកជន និង ការកំណត់គោលដៅមកលើអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅមន្ទីរសន្តិសុខចំនួន ៤ ការដ្ឋានការងារចំនួន ៣ និងសហករណ៍មួយ។ មុនពេលចាប់ផ្តើមការជំនុំជម្រះលើអង្គហេតុនៃការប្រព្រឹត្តិលើជនជាតិចាមនេះ អង្គជំនុំ-ជម្រះសាលាដំបូង សូមរម្លឹកឡើងវិញថា អង្គជំនុំជម្រះបានបញ្ចប់សវនាការសួរដេញដោលលើអង្គហេតុសហករណ៍ និង ការដ្ឋានការងារចំនួន ៣ ដោយបានស្តាប់សក្ខីកម្មរបស់បុគ្គលចំនួន ៦៥ រូបក្នុងនោះរួមមានសាក្សីចំនួន ៣៩ រូប ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៥ រូប និង អ្នកជំនាញចំនួន ១ រូប នៅក្នុងអំឡុងពេលសវនាការចំនួន ៩៨ ថ្ងៃ។

ព័ត៌មានបន្ថែមលើបទចោទប្រកាន់ទាក់ទងនឹងការប្រព្រឹត្តទៅលើជនជាតិចាម លោកអ្នកអាចស្វែងរកបាននៅលើគេហទំព័ររបស់អ.វ.ត.ក http://www.eccc.gov.kh/en/node/34168

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីផ្នែកច្បាប់
ទូរស័ព្ទចល័តៈ +៨៥៥ (០) ១២ ៤៨៨ ០២៣
សារអេឡិកត្រូនិកៈ olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទចល័តៈ +៨៥៥ (០) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិកៈ neth.pheaktra@eccc.gov.kh